# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តឧត្តរមានជ័យ**

<u>សំណុំរឿងព្រហ្មទណ្ឌលេខ ៥២</u>

ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៣

<u>សំណុំរឿងជំនុំជម្រះលេខ ៨៤</u>

ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២៣

<u>សាលក្រមព្រហ្មទណ្ឌលេខ ៥០“ខ”/១៩៦</u>

ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២៣

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តឧត្តរមានជ័យ

បានបើកសវនាការជាសាធារណៈ នៅសាលជំនុំជម្រះនៃសាលាដំបូងខេត្តឧត្តរមានជ័យ នៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០២៣ ពេលព្រឹក ដោយមានសមាសភាពដូចតទៅ:

### សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ នៃសាលាដំបូងខេត្តឧត្តរមានជ័យ

លោក [redacted] ជាចៅក្រមប្រឹក្សា នៃសាលាដំបូងខេត្តឧត្តរមានជ័យ

លោកស្រី [redacted] ជាចៅក្រមប្រឹក្សា នៃសាលាដំបូងខេត្តឧត្តរមានជ័យ

### តំណាងអយ្យការ

លោក [redacted] ជាព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងខេត្តឧត្តរមានជ័យ

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ជាក្រឡាបញ្ជី នៃសាលាដំបូងខេត្តឧត្តរមានជ័យ

### មេធាវី

លោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

### ដើម្បីជំនុំជម្រះ

សំណុំរឿងព្រហ្មទណ្ឌលេខ **៥២** ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៣ ដែលមានជនជាប់ចោទ៖

១.ឈ្មោះ [redacted] **ង៉ុយ** ភេទប្រុស អាយុ១៧ឆ្នាំ កើតឆ្នាំ២០០៥ មុខរបរកសិករ ជនជាតិខ្មែរ ទីកន្លែងកំណើត ភូមិ [redacted] ខេត្តឧត្តរមានជ័យ មានទីលំនៅបច្ចុប្បន្នស្ថិតនៅ [redacted] ខេត្តឧត្តរមានជ័យ នៅលីវ ឪពុកឈ្មោះ [redacted] ង៉ឿត (រស់) ម្ដាយឈ្មោះ [redacted] ទឹម (រស់) កម្រិតវប្បធម៌ថ្នាក់ទី០៤ ទោសពីមុន គ្មាន (ក្នុងឃុំ)

ជាប់ចោទពីបទ **រួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ** ប្រព្រឹត្តនៅចំណុចផ្ទះឈ្មោះ [redacted] ង៉ុយ ស្ថិតនៅភូមិតាម៉ា ឃុំបេង ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ កាលពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យផ្ដន្ទាទោសតាមមាត្រា **៤២** នៃច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ។

**-បានឃើញ** ដីកាដំណោះស្រាយ (បញ្ជូនសំណុំរឿងទៅជំនុំជម្រះ) លេខ ០៥៧ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តឧត្តរមានជ័យ។

**-បានឃើញ** ដីកាចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះ លេខ ០៩៦ ដចត/២៣ ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២៣ របស់ប្រធានសាលាដំបូងខេត្តឧត្តរមានជ័យ។

Scanned with CamScanner

## អង្គហេតុមានដូចតទៅ៖

កាលពីថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០២៣ វេលាម៉ោងដប់បី ឈ្មោះ [redacted] ស្រីចារ ភេទស្រី កើតឆ្នាំ២០០០ បានខលទូរស័ព្ទតាមប្រព័ន្ធហ្វេសបុកឈ្មោះ [redacted] ថៃ ដើម្បីហៅឈ្មោះ [redacted] ង៉ុយ ភេទប្រុស អាយុ ១៧ឆ្នាំ កើតថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៥ ដែលជាសង្សាឱ្យមកយកខ្លួនពីផ្ទះឈ្មោះ ស្រីភាព ដើម្បីយកខ្លួនទៅផ្ទះរបស់ឈ្មោះ [redacted] ង៉ុយ នៅភូមិ តាម៉ា ឃុំ បេង ស្រុក បន្ទាយអំពិល ខេត្ត ឧត្តរមានជ័យ។ បន្ទាប់ពីមកដល់ផ្ទះ ហើយ នៅវេលាម៉ោងដប់ប្រាំមួយ ក៏នាំគ្នាហូបបាយ ក្រោយពីហូបបាយរួច នៅវេលាម៉ោងដប់ប្រាំពីរ ឈ្មោះ [redacted] ង៉ុយ និងឈ្មោះ [redacted] ស្រីចារ បានឡើងទៅបន្ទប់ដេក ភ្លាមនោះក៏បានធ្វើសកម្មភាពរួមភេទជាមួយគ្នារហូត បានសម្រេចចំនួនមួយដង ពិតប្រាកដមែន។

## នាពេលសវនាការ

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនរងគ្រោះ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

-ក្រោយពីបានពិភាក្សាក្រុមប្រឹក្សាជំនុំជម្រះដោយសម្ងាត់រួចរាល់ហើយ។

## តុលាការខេត្តឧត្តរមានជ័យ

## យល់ឃើញថា៖

១.ជនជាប់ចោទឈ្មោះ [redacted] ង៉ុយ ភេទប្រុស អាយុ១៧ឆ្នាំ បានឆ្លើយថា ខ្លួនពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ ប្រាកដមែន។ ឈ្មោះ [redacted] ស្រីចារ ជាសង្សាររបស់ខ្លួន។ កន្លងមកស្គាល់គ្នាតាមហ្វេសប៊ុក នាងប្រាប់ខ្លួនថា នាងមានអាយុ១៧ឆ្នាំ តែខ្លួនមិនបានចាប់អារម្មណ៍នោះទេ។ នៅថ្ងៃកើតហេតុនាងឱ្យខ្លួនទៅយកនាងមកផ្ទះរបស់ខ្លួន រួចខ្លួនក៏បានយកនាងមកផ្ទះរបស់ខ្លួន ពេលនោះផ្ទះរបស់ខ្លួន មានគ្នា ចំនួន ០៦នាក់ ដោយមាន មីង យាយ បងប្អូន។ នៅពេលល្ងាច យាយរបស់ខ្លួនបានឱ្យខ្លួនជូននាងទៅផ្ទះវិញ តែនាងមិនព្រមទៅ រួចក៏ហូបបាយ ពេលហូបបាយរួច ខ្លួនឱ្យនាងទៅគេងជាមួយប្អូនរបស់ខ្លួន តែនាងមកដេកជាមួយខ្លួនរួចក៏បានរួមភេទ។ ខ្លួនពិតជាបានរួមភេទជាមួយគាត់មែន។ ពេលដែលម្តាយខ្លួនសួរនាងថា នាងប្រាប់ថាមានអាយុ១៧ឆ្នាំ ហើយខ្លួនមិនបានដឹងថា ការរួមភេទជាមួយអនីតិជនខុសច្បាប់នោះទេ។

២.ជនរងគ្រោះឈ្មោះ [redacted] ស្រីចារ ភេទស្រី កើតឆ្នាំ២០០៨ បានឆ្លើយថា ខ្លួនមានអាយុ១៥ឆ្នាំ ខ្លួនជាមួយឈ្មោះ [redacted] ង៉ុយ ជាសង្សា។ ខ្លួនស្គាល់គ្នា ចំនួន ០១ខែ ធ្លាប់រួមភេទជាមួយគ្នាបានម្តង រួចប៉ារបស់ខ្លួនបានឱ្យគេចាប់គាត់។ នៅថ្ងៃកើតហេតុគាត់មកយកខ្លួន នៅផ្ទះមិត្តភ័ក្តិរបស់ខ្លួន ពេលនោះមិត្តភ័ក្តិរបស់ខ្លួនថាទៅចុះគាត់ ពេលទៅដល់ផ្ទះរបស់គាត់ គាត់បានឱ្យខ្លួនទៅលើផ្ទះ ពេលទៅផ្ទះរបស់គាត់យាយគាត់សួរ ខ្លួនប្រាប់គាត់ថាមានអាយុ១៥ឆ្នាំ ពេលនោះគាត់មិនបាននៅទេ ពេលរួមភេទនោះគាត់ រៀងបង្ខំដែរដោយគាត់និយាយដដែលៗ ខ្លួនក៏ព្រម។ ការរួមភេទ គឺមុនពេលញ៉ាំបាយ។ ពេលរួមភេទមិនព្រមស្រែក ព្រោះគាត់ចាប់បិទមាត់ខ្លួន ពេលនោះគាត់មិនបានវាយតប

Scanned with CamScanner

អ្វីនោះទេ។ បន្ទាប់ពីរួមភេទរួចក៏ញ៉ាំបាយរួចម៉ោង ៨ យប់ ឪពុកខ្លួនមកយក។ នៅពេលរួមភេទគាត់និយាយថា សុំមួយមក ដដែលក៏ព្រមឱ្យគាត់។ ចំពោះរឿងអាយុគាត់មិនដែលសួរទេ តែគាត់ប្រាក់ថា គាត់អាយុ១៨ឆ្នាំ។

៣.ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សារឿន ភេទប្រុស អាយុ៥១ឆ្នាំ បានឆ្លើយថា សុំទាមទារសំណងចំនួន ៥០០០ដុល្លាអាមេរិក។ ខ្លួនមិនបានដឹងថាកូនមានទំនាក់ទំនងជាមួយគ្នាទេ។ ខ្លួនមិនបានសួរនាំនោះទេ។ នៅថ្ងៃកើតហេតុបានឱ្យសមត្ថកិច្ចហៅឈ្មោះ [redacted] ង៉ុយ ទៅប៉ុស្តិ៍។ នៅថ្ងៃកើតហេតុខ្លួនបានឱ្យមេប៉ុស្តិ៍ទៅឈ្មោះ [redacted] ង៉ុយ យកសាកសួរ ដោយមានការសង្ស័យក៏សួរកូនប្រាប់ថា បានរួមភេទ។

៤.តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា ក្រោយពីបានស្តាប់ការពិភាក្សាដេញដោល រួចមក ឃើញថាជនជាប់ចោទឈ្មោះ [redacted] ង៉ុយ ភេទប្រុស ងាយុ១៧ឆ្នាំ បានធ្វើសកម្មភាពរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំចំនួន ០១លើក នៅផ្ទះរបស់ឈ្មោះ [redacted] ង៉ុយ ស្ថិតនៅភូមិតាម៉ា ឃុំបេង ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ។ តាមសំបុត្រកំណើតរបស់ជនរងគ្រោះឈ្មោះ [redacted] ស្រីចារ កើតនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០៨។ ផ្អែកតាមទឡ្ហីករណ៍ខាងលើជនជាប់ចោទបានប្រព្រឹត្តបទល្មើស រួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ ប្រព្រឹត្តនៅចំណុចផ្ទះឈ្មោះ [redacted] ង៉ុយ ស្ថិតនៅភូមិតាម៉ា ឃុំបេង ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ កាលពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ។ តាមការបញ្ជាក់របស់ជនរងគ្រោះ មានអាយុលើស១៥ឆ្នាំ តាមសំបុត្របញ្ជាក់កំណើតបញ្ជាក់ថា ជនរងគ្រោះមានអាយុក្រោម១៥ឆ្នាំ ហើយថាមិនដឹងថាខុសច្បាប់ នោះទេ គឺមិនអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ។ មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ង៉ុយ ភេទប្រុស ងាយុ១៧ឆ្នាំ ពីបទ រួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ ប្រព្រឹត្តនៅចំណុចផ្ទះឈ្មោះ [redacted] ង៉ុយ ស្ថិតនៅភូមិតាម៉ា ឃុំបេង ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ កាលពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ។ ដូច្នេះស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

៥.មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា ក្រោយពីបានស្តាប់ការពិភាក្សាដេញដោលរួចមក ឃើញថា កូនក្តីរបស់ខ្លួនបានសារភាពថា បានរួមភេទ ប្រាកដមែន។ កូនក្តីរបស់ខ្លួន ជាមួយជនរងគ្រោះ បានព្រមព្រៀងគ្នា តាមចម្លើយបានឆ្លើយថា ខ្លួនមានទំនាក់ទំនងជាមួយគ្នា ចំនួន ០២ខែ មកហើយ។ កូនក្តីរបស់ខ្លួនពុំមានចេតនាទុច្ចរិតនោះទេ ដោយភាគីស្រលាញ់គ្នា បញ្ញាការយល់ដឹងនៅមានកម្រិត។ ផ្អែកតាមអង្គហេតុ គឺជាទំនាក់ទំនងស្នេហា។ ដូច្នេះស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះ ផ្តល់នូវស្ថានសម្រាលតាមមាត្រា ១៦០ និងមាត្រា ១៦៤ នៃក្រមព្រហ្មទណ្ឌ ដល់កូនក្តីរបស់ខ្ញុំបាទ ដោយក្តីអនុគ្រោះ។

៦.ជនជាប់ចោទឈ្មោះ [redacted] ង៉ុយ ភេទប្រុស អាយុ១៧ឆ្នាំ បានសំណូមពរថា គ្មាន។

៧.តាមចម្លើយរបស់ជនជាប់ចោទ តាមចម្លើយរបស់ជនរងគ្រោះ តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងក្រោយពីបានពិនិត្យភស្តុតាងដែលមាននៅក្នុងសំណុំរឿង បានបញ្ជាក់ឱ្យឃើញថា ជនរងគ្រោះឈ្មោះ [redacted] ស្រីចារ ភេទស្រី កើតឆ្នាំ២០០៨ មានអាយុ ១៤ឆ្នាំ ប៉ុន្តែនៅចំពោះមុខតុលាការ ជនរងគ្រោះបានឆ្លើយថាខ្លួនមានអាយុ ១៥ឆ្នាំ។ ចម្លើយរបស់ជនរងគ្រោះ និងរូបរាយកាយសម្បទាជាក់ស្តែងរបស់ជនរងគ្រោះ ព្រមទាំងចម្លើយរបស់ជន

Scanned with CamScanner

ជាប់ចោទ មានភាពស៊ីសង្វាក់គ្នា អាចឱ្យតុលាការជឿបានថា ជនជាប់ចោទមិនបានដឹងថាជនរងគ្រោះមានអាយុក្រោម ១៥ឆ្នាំនោះទេ។

៨.ប្រសិនបើជនជាប់ចោទមិនដឹងថា ជនរងគ្រោះមានអាយុក្រោម ១៥ឆ្នាំ នោះមិនអាចកំណត់ថា ជនជាប់ចោទមានចេតនាប្រព្រឹត្តបទល្មើសរួមភេទជាមួយអនីតិជនក្រោមអាយុក្រោម ១៥ឆ្នាំបានឡើយ។

៩.ពុំមានពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] ង៉ុត ភេទប្រុស អាយុ១៧ឆ្នាំ ពីបទ **រួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ** ប្រព្រឹត្តនៅចំណុចផ្ទះឈ្មោះ [redacted] ង៉ុយ ស្ថិតនៅភូមិតាម៉ា ឃុំបេង ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ កាលពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ។

## ហេតុដូច្នេះតុលាការ
## វិនិច្ឆ័យសេចក្តី

**-ឱ្យរួចផុតពីបទចោទប្រកាន់លើឈ្មោះ** [redacted] ង៉ុយ ភេទប្រុស អាយុ១៧ឆ្នាំ ជនជាតិខ្មែរ (អត្តសញ្ញាណខាងលើ) ពីបទ **រួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ** ប្រព្រឹត្តនៅចំណុចផ្ទះឈ្មោះ [redacted] ង៉ុយ ស្ថិតនៅភូមិតាម៉ា ឃុំបេង ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ កាលពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០២៣ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២៣ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ង៉ុយ និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សារឿន។

បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់៕

ថ្ងៃពុធ ៧កើត ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅឧត្តរមានជ័យ, ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២៣

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

[redacted]

---

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"
ថ្ងៃពុធ ៧កើត ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅឧត្តរមានជ័យ, ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២៣
**ក្រឡាបញ្ជីសវនាការ**

[redacted]

**បានឃើញ**
ឧត្តរមានជ័យ,ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២៣
**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

Scanned with CamScanner